## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ទីភ្នាក់ងារជ្រើសរើសឯកជនដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបណ្តាប្រទេសអារ៉ាប់

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ ឱ្យបានជ្រាបថា ទីភ្នាក់ងារជ្រើសរើសឯកជនដែលមានសិទ្ធិធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបណ្តាប្រទេសអារ៉ាប់ ចំនួន ១ ដែលមានសកម្មភាព ដូចមានឈ្មោះខាងក្រោម៖

| ល.រ<br>No. | លេខបញ្ជី<br>Registration Number | ឈ្មោះក្រុមហ៊ុន<br>Company Name | ឆ្នាំចុះបញ្ជី<br>Year of Registration | អាសយដ្ឋាន<br>Address | លេខទូរសព្ទ<br>Telephone |
|---|---|---|---|---|---|
| 1 | 168 | **ផេស៊ីហ្វិក អ៊ីមផ្លយមិន អេជេន ខ.ក**<br>PACIFIC EMPLOYMENT AGENT CO., LTD. | 2024 | ផ្ទះលេខ១៥H ផ្លូវលេខ៣៧១ ភូមិត្រា៣ សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>No.15H, St.371, Phum Trea3, Sangkat Stueng Mean Chey1, Khan Mean Chey, Phnom Penh. | 016 770 870<br>077 770 870<br>066 770 870 |

បងប្អូនដែលមានបំណងស្វែងរកការងារធ្វើនៅបណ្តាប្រទេសអារ៉ាប់ អាចពិនិត្យមើលបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន ដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh ឬអាចជ្រើសរើសទីភ្នាក់ងារជ្រើសរើសឯកជន និងចុះឈ្មោះស្វែងរកការងារធ្វើនៅបណ្តាប្រទេសអារ៉ាប់ ដោយផ្ទាល់តាមកម្មវិធីទូរសព្ទដៃ "**MLVT Services**" ឬតាមទូបញ្ជរសេវាសាធារណៈចល័តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាននៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួង ស្ថាប័នផ្សេងៗ ផ្សារទំនើប ហាងកាហ្វេ ម៉ាតធំៗ និងទីប្រជុំជនសំខាន់ៗ នៅក្នុងរាជធានីភ្នំពេញ។ លោកអ្នកក៏អាចស្វែងរកបញ្ជីឈ្មោះ និងឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន និងអាចតាមដានដំណើរការឯកសារចាប់ពីការចុះឈ្មោះស្វែងរកការងារធ្វើនៅបណ្តាប្រទេសអារ៉ាប់ រហូតដល់ធ្វើមាតុភូមិនិវត្តន៍មកប្រទេសកំណើតវិញ ដោយខ្លួនឯងផ្ទាល់តាមរយៈតំណភ្ជាប់ https://tracking.ocwc.co/។

រាល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងឡាយណាដែលមិនមានឈ្មោះក្នុងបញ្ជីខាងលើនេះ គឺចាត់ទុកថាជាទីភ្នាក់ងារជ្រើសរើសឯកជនខុសច្បាប់ ដូច្នេះសូមសាធារណជនរាយការណ៍ជាបន្ទាន់មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈ Hotline លេខ១២៨៦/១២៩៧ លេខទូរសព្ទ ០១៥ ៧៨៦ ៩៨៩ ឬគ្រុបតេឡេក្រាម "**សម្រាប់ ពលករទេសន្តរប្រវេសន៍**" តាមតំណភ្ជាប់ https://t.me/KhmerMigrantWorker ឬទំនាក់ទំនងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥ រាជធានី ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៨៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ដើម្បីជៀសវាងការផ្សព្វផ្សាយព័ត៌មានខុស ដែលអាចនាំឱ្យប្រជាពលរដ្ឋរងគ្រោះ ដោយសារការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងការជ្រើសរើស ឬផ្តល់សេវារកការងារឱ្យធ្វើនៅបរទេសដល់ពលករខ្មែរនៅតាមបណ្តាសារព័ត៌មានណាមួយ ជាពិសេសតាមបណ្តាស្ថានីយ៍វិទ្យុត្រូវមានលិខិតអនុញ្ញាតចេញដោយអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមុន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន អង្គភាពពាក់ព័ន្ធ បណ្តាសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន និងសហការអនុវត្ត។

ថ្ងៃ សុក្រ ៧កើត ខែ អស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០២៥

"សម្រាប់ពលករទេសន្តរប្រវេសន៍"

"MLVT Services"